**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ២៥៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

**គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ** សរសេរជាអក្សរកាត់ថា "គ.អ.ហ." ត្រូវបានបង្កើតឡើងជាសេនាធិការមួយរបស់ **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**។

**មាត្រា២ .-**

ការបង្កើត គ.អ.ហ. មានគោលដៅជំរុញ និងធានាឱ្យបាននូវការអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយភាពរឹងមាំ និងស្ថិរភាព។

**មាត្រា៣ .-**

គ.អ.ហ. មានតួនាទីជាសេនាធិការរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញ-វត្ថុ ក្នុងការអនុវត្តការងារ ដូចខាងក្រោម÷

- ដឹកនាំ សម្របសម្រួល តាមដាន និងត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ**" របស់រាជរដ្ឋាភិបាល។
- រៀបចំ និងធ្វើបច្ចុប្បន្នកម្ម "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ**" តាមការចាំបាច់។
- ផ្តួចផ្តើម និងដាក់ចេញនូវវិធានការសមស្រប ដើម្បីជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្លើយតបទៅនឹងគោលបំណងរបស់ "**យុទ្ធសាស្ត្រចតុកោណ**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**" របស់រាជរដ្ឋាភិបាល។
- សម្របសម្រួល និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ សម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។
- អនុវត្តកិច្ចការផ្សេងទៀតតាមការចង្អុលបង្ហាញរបស់ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាល។

## ជំពូកទី២
## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា៤ .-**

គ.អ.ហ. មានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | អនុប្រធានប្រចាំការ |
| ៤- | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥- | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៦- | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៧- | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

៨- អគ្គនាយកនៃនិយ័តករ និងប្រធានអង្គភាពក្រោមឱវាទ
អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សមាជិក

៩- អគ្គលេខាធិការធនាគារជាតិនៃកម្ពុជា សមាជិក

១០- អគ្គនាយកបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា សមាជិក

១១- អគ្គនាយកត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា សមាជិក

១២- អគ្គនាយករងបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា ១ (មួយ) រូប សមាជិកនិងលេខាធិការ។

សមាសភាពជាក់ស្តែងនៃ **គ.អ.ហ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

ដើម្បីបំពេញមុខងារ តួនាទី និងភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ ប្រកបដោយប្រសិទ្ធភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល, **គ.អ.ហ.** ត្រូវមាន **ក្រុមការងារបច្ចេកទេស** ចំនួន ២ ជាសេនាធិការ ដែល **ក្រុមការងារបច្ចេកទេសទី១** ស្ថិតក្រោមការគ្រប់គ្រងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង **ក្រុមការងារបច្ចេកទេសទី២** ស្ថិតក្រោមការគ្រប់គ្រងនៃធនាគារជាតិនៃកម្ពុជា។

តួនាទី និងភារកិច្ចនៃក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## ដំណើរការការងារ

**មាត្រា៦ .-**

**គ.អ.ហ.** ត្រូវរៀបចំកិច្ចប្រជុំយ៉ាងតិច ៣ (បី) ដង ក្នុង ១ (មួយ) ឆ្នាំ និង/ឬ តាមការចាំបាច់ និងត្រូវរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពអភិវឌ្ឍវិស័យហិរញ្ញវត្ថុជូន គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧ .-**

តាមការអញ្ជើញរបស់ប្រធាន **គ.អ.ហ.**, អនុប្រធាន សមាជិក និងលេខាធិការនៃ **គ.អ.ហ.** ត្រូវចូលរួមកិច្ចប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចដើម្បីចូលរួមជំនួស ក្នុងករណីអវត្តមាន។

អនុប្រធាន **គ.អ.ហ.** មានសិទ្ធិស្នើប្រធាន **គ.អ.ហ.** ដើម្បីរៀបចំកិច្ចប្រជុំស្របតាមខ្លឹមសារមាត្រា៦ នៃអនុក្រឹត្យនេះ និងអាចដឹកនាំកិច្ចប្រជុំជំនួស តាមការប្រគល់សិទ្ធិរបស់ប្រធាន **គ.អ.ហ.**។

**មាត្រា៨ .-**

**គ.អ.ហ.** មានសិទ្ធិអញ្ជើញមន្ត្រីផ្សេងៗទៀតនៃក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចូលរួមការងារតាមការចាំបាច់។

ប្រធាន **គ.អ.ហ.** មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀតចូលរួមកិច្ចប្រជុំ តាមការចាំបាច់។

**មាត្រា៩ .-**

**គ.អ.ហ.** មានលេខាធិការដ្ឋានមួយនៅធនាគារជាតិនៃកម្ពុជា ជាសេនាធិការ សម្រាប់បំពេញមុខងាររបស់ខ្លួន។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន **គ.អ.ហ.** ត្រូវកំណត់ដោយប្រកាសរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា ដែលជាប្រធាន **គ.អ.ហ.**។

**គ.អ.ហ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១០ .-**

អនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៤ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច/ឯកឧត្ដម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ